00812091

E191/2

សាធារណៈ / Public

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 06 / 2012
ម៉ោង (Time/Heure): 09:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម និល ណុន ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

កាលបរិច្ឆេទ: ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១២
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង សារី សុំប្តឹងដិតចិត្តលោកស្រីចៅក្រម CARTWRIGHT

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងរបស់ អៀង សារី នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ដែលស្នើសុំអង្គជំនុំជម្រះឱ្យដកចិត្តលោកស្រីចៅក្រម CARTWRIGHT អនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ឬ ជាជម្រើសផ្សេង សុំអង្គជំនុំជម្រះណែនាំដល់លោកស្រីចៅក្រម CARTWRIGHT និងបង្គាប់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew CAYLEY បញ្ឈប់ និងឈប់ការប្រាស្រ័យទាក់ទង និងជួបប្រជុំជាមួយ*តែភាគីម្ខាង (ex parte)* និងចម្លងនូវការប្រាស្រ័យទាក់ទងទាំងអស់រវាងពួកគេនាពេលអនាគត ជូនដល់តំណាងពីអង្គការគាំពារការការពារក្តី (“DSS”) ឬក្រុមមេធាវីការពារក្តី[1]។ អៀង សារី ក៏បានស្នើសុំថាអង្គជំនុំជម្រះគួរណែនាំលោកស្រីចៅក្រម CARTWRIGHT និងបង្គាប់លោក CAYLEY ឱ្យបញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* ទាំងអស់ដែលបានធ្វើឡើង ចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មក ដែលរួមទាំងលិខិតឆ្លើយឆ្លងគ្នា និងចំនួននៃការជួបប្រជុំ កាលបរិច្ឆេទនៃការជួបប្រជុំ របៀបវារៈនៃការជួបប្រជុំ ដែលពាក់ព័ន្ធនឹងការជួបប្រជុំ*ជាមួយភាគីតែម្ខាង* និងវិធានការនានាដែលបានធ្វើនៅឯការជួបប្រជុំ និងដោយអនុលោមតាមការជួបប្រជុំទាំងនោះ។

## ២. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តី នួន ជា បានដាក់បណ្តឹងតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង ដែលសុំប្តឹងដកចិត្តលោកស្រីចៅក្រម CARTWRIGHT ដោយសំអាងទៅលើការជួបប្រជុំក្រៅផ្លូវការទាំងឡាយ ដែលបានធ្វើឡើងជាទៀងទាត់ រវាងលោកស្រីចៅក្រម CARTWRIGHT លោក CAYLEY និងអនុប្រធានការិយាល័យរដ្ឋបាល អ.វ.ត.ក លោក Knut ROSANDHAUG (“ការជួបប្រជុំ”)[2]។ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវី

[1] បណ្តឹងរបស់ អៀង សារី សុំប្តឹងដកចិត្តលោកស្រីចៅក្រម Silvia CARTWRIGHT អនុលោមតាមវិធាន ៣៤ ឬ ជាជម្រើសផ្សេងទៀត សំណើសុំការណែនាំ និងបង្គាប់ឱ្យបញ្ឈប់ និងឈប់ការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង (Ex Parte)* និងសំណើសុំឱ្យបញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទងនានាជាមួយ*តែភាគីម្ខាង (Ex Parte)*, ឯកសារលេខ E191, ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ (“បណ្តឹង”)។

[2] បណ្តឹងរបស់មេធាវីការពារក្តី នួន ជា សុំប្តឹងដកចិត្តជាបន្ទាន់ចំពោះលោកស្រីចៅក្រម CARTWRIGHT, ឯកសារលេខ E137/2, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។

ការពារក្ដី អៀង សារី បានលើកសំណើសុំឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ទៅលើការជួបប្រជុំនានា អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង[3]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលបណ្ដឹងទាំងនេះនៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១[4]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធចោលបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី អៀង សារី ជំទាស់នឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើបណ្ដឹងរបស់ខ្លួន អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២[5]។

៣. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២ សារអេឡិចត្រូនិកមួយត្រូវបានផ្ញើដោយភាន់ច្រឡំពីលោកស្រីចៅក្រម CARTWRIGHT ទៅបុគ្គលិក អ.វ.ត.ក មួយចំនួន ដែលមានខ្លឹមសារដូចខាងក្រោម ("សារអេឡិចត្រូនិកទីមួយ")៖

> តាមពិតខ្ញុំបានកំពុងព្យាយាមសម្លឹងមើលចំណុចស្រាលជាងនេះប៉ុណ្ណោះ។
>
> ដូចលោកដឹងស្រាប់ហើយ Andrew ខ្ញុំកំពុងតែពិចារណាយ៉ាងយកចិត្តទុកដាក់ចំពោះជំហររបស់ខ្ញុំ។ ខ្ញុំមិនត្រូវសម្រេចសេចក្ដីដោយប្រញាប់ប្រញាល់នោះទេ។ [*sic*]
>
> ពីខ្ញុំ Silvia

៤. ជាការឆ្លើយតបទៅនឹងសំណើសុំការបញ្ជាក់ពីអ្នកតំណាងមេធាវីការពារក្ដី អៀង សារី នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១២ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងអ្នកស្រី Susan LAMB បានផ្ញើសារអេឡិចត្រូនិកមួយ ("សារអេឡិចត្រូនិកទីពីរ") ដែលមានខ្លឹមសារថា៖

---

[3] សំណើរបស់លោក អៀង សារី ស្នើឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម CARTWRIGHT និងអ្នកដទៃទៀត, ឯកសារលេខ E137/3, ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[4] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចៅក្រម Silvia CARTWRIGHT, ឯកសារលេខ E137/5, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១, ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទីបួន")។

[5] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីបណ្ដឹងជំទាស់លោកស្រីចៅក្រម Silvia CARTWRIGHT, ឯកសារលេខ E137/5/1/3, ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ")។

ជូនចំពោះលោកស្រី Pettay

នាងខ្ញុំបានទទួលសំណើសុំឱ្យផ្តល់ជូននូវព័ត៌មានខាងក្រោមនេះដល់លោកស្រី ជាការឆ្លើយតបទៅនឹងសារអេឡិចត្រូនិក ដែលលោកស្រីបានផ្ញើមកនាងខ្ញុំកាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១២៖

"សារអេឡិចត្រូនិកដែលបានផ្ញើចេញកាលពីម្សិលមិញមានបំណងផ្ញើជូនអ្នកទទួលមួយចំនួន រួមមាន អនុប្រធានការិយាល័យរដ្ឋបាល និងលោក Andrew Cayley ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ។

សារនោះមួយផ្នែកគឺជាការសង្ខេបនៃកិច្ចពិភាក្សា រវាងលោកស្រីចៅក្រម Cartwright លោក Cayley និង លោក Rosandhaug ពាក់ព័ន្ធនឹងប្រតិកម្មសមស្របទៅនឹងសេចក្តីសម្រេចរបស់ អ.ជ.ត.ក នាពេលថ្មីៗនេះ ដែលបដិសេធបណ្តឹងសាទុក្ខមួយប្រឆាំងនឹងការបដិសេធមិនឱ្យលោកស្រីចៅក្រម ចូលរួមជំនុំជម្រះ។

កិច្ចប្រជុំរៀបចំសវនាការ ដែលជាប្រធានបទនៃការប្តឹងសុំឱ្យបដិសេធមិនឱ្យលោកស្រីចៅក្រមចូលរួមនោះ ត្រូវបានធ្វើឡើងទៅតាមសំណើរបស់ការិយាល័យច្បាប់ តែអនុលោមតាមយោបល់របស់ អ.ជ.ត.ក ពួកគេបានសម្រេចមិនបន្តកិច្ចប្រជុំនោះទៀតទេ។

បញ្ហាពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលនាពេលខាងមុខ នឹងត្រូវដោះស្រាយដោយផ្ទាល់ជាមួយការិយាល័យរដ្ឋបាលតែម្តង"។

សូមទទួលនូវការរាប់អានពីនាងខ្ញុំ

Susan LAMB

៥. សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងបណ្តឹងរបស់ អៀង សារី នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២[6]។ លោកស្រីចៅក្រម CARTWRIGHT បានជ្រើសរើសមិនប្រើប្រាស់សិទ្ធិរបស់ខ្លួន

---

6 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងរបស់ អៀង សារី ប្តឹងជំទាស់លោកស្រីចៅក្រម Silvia CARTWRIGHT អនុលោមតាមវិធាន ៣៥ ឬជាជម្រើសផ្សេងទៀត សំណើសុំការណែនាំ និងបង្គាប់ឱ្យបញ្ឈប់ និងឈប់ធ្វើការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* និងសំណើសុំឱ្យបញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទងនានាជាមួយ *តែភាគីម្ខាង*', ឯកសារលេខ E191/1, ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ("ចម្លើយតប")។

ដើម្បីដាក់សារណាជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះទេ[7]។

## ៣. សារណា

៦. ជនជាប់ចោទ អៀង សារី អះអាងថា សារអេឡិចត្រូនិកទីមួយ និងទីពីរពេលអានរួមគ្នាបង្ហាញថា ការពិភាក្សាជាមួយ *តែភាគីម្ខាង* បានកើតមានរវាងចៅក្រម CARTWRIGHT និងលោក CAYLEY ដែលពាក់ព័ន្ធទៅនឹងខ្លឹមសារនៃកិច្ចនីតិវិធីក្នុងសំណុំរឿង០០២[8]។ យោងតាមជនជាប់ចោទ អៀង សារី ការពិភាក្សានេះសបញ្ជាក់ឱ្យឃើញនូវភាពលម្អៀងជាក់ស្ដែង ឬភាពលម្អៀងដោយប្រយោលរបស់ចៅក្រម CARTWRIGHT ដោយហេតុថា ការពិភាក្សានេះបង្ហាញឱ្យឃើញអំពីភាពមិនប្រក្រតីនៃការប្រាស្រ័យទាក់ទង របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយចៅក្រមជំនុំជម្រះ។ ដោយហេតុថាចៅក្រម CARTWRIGHT ពុំអនុញ្ញាតឱ្យអ្នកតំណាងរបស់ក្រុមមេធាវីការពារក្ដីប្រាស្រ័យទាក់ទងការងារជាមួយគាត់ដោយផ្ទាល់ ទើបមានភាពលម្អៀងលើការយកចិត្តទុកដាក់របស់លោកស្រីចៅក្រម រវាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដី[9]។

៧. ជនជាប់ចោទ អៀង សារី អះអាងថា ចៅក្រម CARTWRIGHT "ពុំបានអើពើដល់ការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង ទាក់ទិននឹងអានុភាពគតិយុត្តនៃការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង*" នោះទេ[10]។ គាត់អះអាងទៀតថា "ការចែករំលែកព័ត៌មានជាមួយ *តែភាគីម្ខាង* ទាក់ទិននឹងយុត្តិសាស្ត្រនៃសំណុំរឿង ០០២" រវាងចៅក្រម CARTWRIGHT និងលោក CAYLEY បូករួមទាំង "ការខកខានរបស់ចៅក្រម CARTWRIGHT ក្នុងការបញ្ចេញឱ្យដឹងអំពីលក្ខណៈនៃការចូលរួមរបស់គាត់" នៅក្នុងកិច្ចប្រជុំនានា មុនពេលមេធាវីការពារក្ដីលើកបញ្ហានេះ ញ៉ាំងឱ្យមានការស្ដែងចេញនូវភាពលម្អៀងដោយយោងតាមយុត្តិសាស្ត្រអន្តរជាតិ[11]។

---

[7] *សូមមើល* វិធានផ្ទៃក្នុង ៣៧(៧)។

[8] បណ្ដឹង, កថាខណ្ឌ ៧,៩,១១,១៥។

[9] បណ្ដឹង, កថាខណ្ឌ ៨,១២-១៥។

[10] បណ្ដឹង, កថាខណ្ឌ ១០។

[11] បណ្ដឹង, កថាខណ្ឌ ១១ (ដោយលើកឡើងនូវសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Karemera*, សំអាងហេតុសម្រាប់សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខបន្ទាន់បន្ទំ ពាក់ព័ន្ធនឹងការបន្តកិច្ចដំណើរការនីតិវិធីជាមួយចៅក្រមបម្រុង និងស្ដីពីសំណើរបស់

៨. បើនៅក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់ប្ដឹងជំទាស់ ដោយអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងទេនោះ ជនជាប់ចោទ អៀង សារី ស្នើសុំអង្គជំនុំជម្រះធ្វើការណែនាំដល់ចៅក្រម CARTWRIGHT និងបង្គាប់ឱ្យលោក CAYLEY បញ្ឈប់ការប្រាស្រ័យទាក់ទងការងារជាមួយ*តែភាគីម្ខាង* តទៅទៀត និងផ្ញើឯកសារចម្លងនៃការប្រាស្រ័យទាក់ទងការងារ ទាក់ទិននឹង អ.វ.ត.ក នាពេលខាងមុខទៅកាន់តំណាងនៃអង្គភាពគាំពារការការពារក្តី ឬក្រុមមេធាវីការពារក្តី។ ជនជាប់ចោទ អៀង សារី ក៏ស្នើសុំឱ្យអង្គជំនុំជម្រះ បង្គាប់ឱ្យមានការបញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទងណាមួយដែលមានជាមួយ*តែភាគីម្ខាង* រវាងចៅក្រម CARTWRIGHT និងលោក CAYLEY ដែលបានធ្វើចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ជនជាប់ចោទ អៀង សារី ពុំបានបញ្ជាក់មូលដ្ឋានគតិយុត្តនៃសំណើទាំងនេះឡើយ[12]។

៩. សហព្រះរាជអាជ្ញាឆ្លើយតបថា សំណើរបស់ជនជាប់ចោទ អៀង សារី គឺពុំអាចឱ្យទទួលយកបានឡើយ ដោយហេតុថា ជនជាប់ចោទខកខានពុំបានបង្ហាញមូលដ្ឋានភស្តុតាងមួយដើម្បីគាំទ្រដល់មូលដ្ឋាននៃបណ្តឹងជំទាស់របស់ខ្លួន[13]។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាអះអាងថាជនជាប់ចោទ អៀង សារី ខកខានពុំបានអនុវត្តកាតព្វកិច្ចរបស់គាត់ក្នុងការបង្ហាញភស្តុតាងដោយអនុលោមតាម ៣៤ នៃវិធានផ្ទៃក្នុង ដោយហេតុថា ការប្រាស្រ័យទាក់ទងការងាររវាងចៅក្រម CARTWRIGHT និងលោក CAYLEY ពុំបានពាក់ព័ន្ធទៅនឹងខ្លឹមសារនៃកិច្ច ដំណើរការនីតិវិធីឡើយ ហើយទោះបីជាយ៉ាងណាក៏ដោយ ការប្រាស្រ័យទាក់ទងការងារនេះក៏ពុំបញ្ជាក់ការពិតដល់ការចោទប្រកាន់អំពីភាពលម្អៀងជាក់ស្តែង ឬភាពលម្អៀងដោយ ប្រយោលនោះទេ[14]។

១០. សហព្រះរាជអាជ្ញាក៏អះអាងថា សំណើរបស់ជនជាប់ចោទ អៀង សារី សុំឱ្យមានការបញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទងនានាជាមួយភាគីតែម្ខាង គួរត្រូវបានបដិសេធ ដោយហេតុថា

---

Nzirorera សុំរយៈពេលដើម្បីពិចារណាលើសម្ភារៈថ្មី, អង្គជំនុំជម្រះតុលាការឧទ្ធរណ៍នៃតុលាការ ICTR, លេខសំណុំរឿង ICTR-98-44-AR15 *ស្ទួន* 2, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បន្ថែ *Karemera*")។

[12] បណ្តឹង, កថាខណ្ឌ ១៧-២២។

[13] ចម្លើយតប, កថាខណ្ឌ ៩-១១។

[14] ចម្លើយតប, កថាខណ្ឌ ១២-១៦,២០-២១,២៣,២៧-២៩។

សំណើនេះគ្រាន់តែលើកឡើងជាថ្មីនូវសំណើមុនតែប៉ុណ្ណោះ ដែលត្រូវបានបដិសេធនៅដំណាក់កាលដំបូង និងនៅដំណាក់កាលបណ្តឹងសាទុក្ខរួចហើយ ហើយពុំមានមូលដ្ឋានគតិយុត្តណាមួយសម្រាប់ធ្វើការបង្គាប់តាមសំណើនោះឡើយ[15]។

១១. ជាចុងក្រោយ សហព្រះរាជអាជ្ញាអះអាងថា សំណើរបស់ជនជាប់ចោទ អៀង សារី ស្នើសុំដំណោះស្រាយជាជម្រើសផ្សេងមួយទៀត ខ្វះមូលដ្ឋានអង្គច្បាប់ ដោយហេតុថា សំណើនេះពុំស្ថិតនៅក្នុងវិសាលភាពនៃវិធាន ៣៤ និងវិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ[16]។

## ៤. សំអាងហេតុ

### ៤.១. ក្របខ័ណ្ឌគតិយុត្ត

#### *៤.១.១ វិធាន ៣៤ នៃវិធានផ្ទៃក្នុង*

១២. វិធាន ៣៤ នៃវិធានផ្ទៃក្នុងចែងអំពីការដាក់បណ្តឹងជំទាស់ចំពោះចៅក្រម។ វិធាន ៣៤(២) ចែងថា៖

> ភាគីអាចធ្វើបណ្តឹងជំទាស់ចំពោះសហចៅក្រមស៊ើបអង្កេត ឬ ចៅក្រមនៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ហិរញ្ញវត្ថុ ឬ មានការពាក់ព័ន្ធ ដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដ ដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលម្អៀង។

១៣. ការស្តែងឱ្យឃើញនូវភាពលម្អៀងអាចកើតមានប្រសិនបើ "ចៅក្រមមួយរូបគឺជាភាគីក្នុងរឿងក្តី ឬមានប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្ទាល់ខ្លួនដែលកើតចេញពីលទ្ធផលនៃរឿងក្តី ឬប្រសិនបើសេចក្តីសម្រេចរបស់ចៅក្រមរូបនោះ នឹងឈានទៅរកការលើកស្ទួយបុព្វហេតុមួយដែលគាត់មានចំណែកក្នុងនោះ ឬកាលៈទេសៈមួយចំនួនអាចនាំឱ្យអ្នកសង្កេតការណ៍បុរកបដោយវិចារណញ្ញាណម្នាក់ ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ យល់បានថាមាន

---

[15] ចម្លើយតប, កថាខណ្ឌ ៣០-៣៩។

[16] ចម្លើយតប, កថាខណ្ឌ ៤១-៤២។

ភាពលម្អៀង"[17]។ ដូចការកត់សម្គាល់ជាប្រចាំរបស់អង្គជំនុំជម្រះសាលាដំបូង អ្នកសង្កេតការណ៍ប្រកបដោយវិចារណញ្ញាណនៅក្នុងន័យនេះគឺជា "មនុស្សម្នាក់ដែលទទួលបានព័ត៌មានគ្រប់គ្រាន់ មានការយល់ដឹងរាល់កាលៈទេសៈដែលពាក់ព័ន្ធ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិ ដែលបង្កើតជាផ្នែកមួយនៃសាវតារ និងបានយល់ដឹងអំពីការពិតដែលថា អនាគតិគឺជាករណីយកិច្ចមួយក្នុងចំណោមករណីកិច្ចដទៃទៀតដែលចៅក្រមត្រូវប្រកាន់ខ្ជាប់"[18]។ ហេតុដូច្នេះ ចំណុចចាប់ផ្ដើម នៃការកំណត់អំពីភាពលម្អៀងរបស់ចៅក្រម គឺការសន្និតអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម អ.វ.ត.ក ផ្អែកលើការធ្វើសច្ចាប្រណិធានចូលកាន់តំណែង និងលក្ខណៈសម្បត្តិសម្រាប់ការតែងតាំងពួកគាត់ជាចៅក្រម[19]។ ភាគីប្ដឹងជំទាស់មានបន្ទុកក្នុងការបដិសេធការសន្និតនោះ ដែលមានលក្ខខណ្ឌខ្ពស់[20]។

១៤. វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង តម្រូវថា ភាគីស្នើសុំប្ដឹងជំទាស់ចៅក្រម "ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីមូលដ្ឋាន និងផ្ដល់ភស្តុតាងគាំទ្រ"។ បណ្ដឹងដែលមានភាពស្មានៗ ឬផ្អែកលើ "ការ

---

[17] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចំពោះចៅក្រម Silvia CARTWRIGHT, ឯកសារ E171/2, ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១២ ("សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទីប្រាំ"), កថាខណ្ឌ ១២; សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី ៤, កថាខណ្ឌ ១៣ (ដោយបានលើកឡើងនូវសំណុំរឿង *ព្រះរាជអាជ្ញា ទល់នឹង Furundžija*, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY , លេខសំណុំរឿង (IT-95-17/1-A), ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ("សាលដីកាលើបណ្ដឹងសាទុក្ខ *Furundžija*"), កថាខណ្ឌ ១៨៩) ។

[18] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី៥, កថាខណ្ឌ ១២, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី ៤, កថាខណ្ឌ ១៤ (ដែលបានលើកឡើងនូវសាលដីកាលើបណ្ដឹងសាទុក្ខ *Furundžija*, កថាខណ្ឌ ១៩០)។

[19] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី៥, កថាខណ្ឌ ១២, សេចក្ដីសម្រេចលើបណ្ដឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្ដឹងជំទាស់ចំពោះលោកចៅក្រម និល ណុន, ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី, ឯកសារ E55/4, ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ១២, សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី ៤, កថាខណ្ឌ ១៤; សេចក្ដីសម្រេចស្ដីពីបណ្ដឹងជំទាស់ជាបន្ទាន់របស់សហមេធាវីចំពោះលោកចៅក្រម ន័យ ធុល ដោយរង់ចាំបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងសំណុំរឿង នួន ជា , ឯកសារ C11/29, ឯកសារថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, កថាខណ្ឌ ១៥-១៧ (ដោយបានលើកឡើងនូវសាលដីកាលើបណ្ដឹងសាទុក្ខ *Furundžija* កថាខណ្ឌ ១៩៦)។

[20] សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី៥, កថាខណ្ឌ ១២; សេចក្ដីសម្រេចលើបណ្ដឹងជំទាស់លើកទី ៤, កថាខណ្ឌ ១៤; *សូមមើលផងដែរ* សាលដីកាលើបណ្ដឹងសាទុក្ខ *Furundžija*, កថាខណ្ឌ ១៩៧ (ដែលបានកត់សម្គាល់ថាចៅក្រមវិជ្ជាជីវៈមានសមត្ថភាព "បែងចែកការគិតរបស់ផងខ្លួន ពីជំនឿ ឬការសន្និតផ្ទាល់ខ្លួនដែលពុំពាក់ព័ន្ធ")។

យល់ឃើញ ឬការសង្ស័យថាមានភាពលម្អៀង” ពីសំណាក់ជនជាប់ចោទណាម្នាក់នោះ គឺមិនគ្រប់គ្រាន់ឡើយ[21]។

### ៤.១.២ *កិច្ចប្រជុំ*

១៥. អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលធ្លាប់បានធ្វើការកត់សម្គាល់ថា កិច្ចប្រជុំរវាងចៅក្រម សហព្រះរាជអាជ្ញា និងមន្ត្រីរដ្ឋបាល គឺជារឿងសាមញ្ញ នៅឯតុលាការអន្តរជាតិ និងតុលាការអន្តរជាតុបនីយកម្មផ្សេងៗ[22]។ កិច្ចប្រជុំទាំងប៉ុន្មាននៅ អ.វ.ត.ក នេះមានគោលបំណងដូចគ្នា ទៅនឹងកិច្ចប្រជុំនៅឯតុលាការខាងលើដែរ ហើយ ដោយហេតុថា កិច្ចប្រជុំទាំងនោះទៀតសោត ពាក់ព័ន្ធតែនឹងបញ្ហារដ្ឋបាល បញ្ហានៃការគ្រប់គ្រង ដែលប៉ះពាល់ដល់ភាគីអន្តរជាតិនៃ អ.វ.ត.ក ជាជាងខ្លឹមសារនៃកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះសាលា-ដំបូងបានសម្រេចរួចហើយថា កិច្ចប្រជុំទាំងនោះ ពុំប៉ះពាល់ដល់ការសន្មតនៃភាពអនាគតិរបស់ចៅក្រម CARTWRIGHT ឡើយ[23]។

១៦. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នៅក្នុងផ្នែកសម្អាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួនថា ការប្រជុំទាំងនេះពុំញ៉ាំងឱ្យមានមូលហេតុមួយដែលអាចឱ្យជឿបានថា អ្នកចូលរួមក្នុងកិច្ចប្រជុំទាំងនេះ ពិតជាបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការដោយចេតនាពិតប្រាកដឡើយ[24]។

## ៤.២ ការវិភាគ

១៧. តាមរយៈសារអេឡិចត្រូនិកទីមួយ និងទីពីរ គឺបង្ហាញឱ្យឃើញថា ការប្រាស្រ័យទាក់ទង

---

[21] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តលើកទី៥ , កថាខណ្ឌ ១៣; សេចក្តីសម្រេចលើបណ្តឹងជិតចិត្តលើកទី ៤, កថាខណ្ឌ ១៤, (ដែលបានលើកឡើងនូវសំណុំរឿង *រដ្ឋអាជ្ញា ទល់នឹង Karemera et al.*, សេចក្តីសម្រេចលើសំណើរបស់ Joseph Nzirorera សុំប្តឹងជិតចិត្តចំពោះចៅក្រម Judge Byron និងស្នើសុំបង្អង់កិច្ចដំណើរការនីតិវិធី, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR , លេខសំណុំរឿង ICTR-98-44-T, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩, កថាខណ្ឌ៥)។

[22] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តលើកទី៤, កថាខណ្ឌ ១៩, សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ, កថាខណ្ឌ ២៣ (ដែលបានកត់សម្គាល់ថាវិធាន៣៥ នៃវិធានផ្ទៃក្នុង លាតសន្ធឹងត្រឹមតែទៅដល់ទង្វើនានាដែលធ្វើឱ្យខូចដំណើរការតាមផ្លូវតុលាការប៉ុណ្ណោះ ប៉ុន្តែផ្ទុយទៅវិញកិច្ចប្រជុំទាំងនោះមានគោលបំណងសម្របសម្រួលកិច្ចដំណើរការនីតិវិធីសវនាការ)។

[23] សេចក្តីសម្រេចលើបណ្តឹងជិតចិត្តលើកទី៤, កថាខណ្ឌ ១៩-២២។

[24] សេចក្តីសម្រេចលើបណ្តឹសាទុក្ខ, កថាខណ្ឌ ២៣។

ការងាររវាងចៅក្រម CARTWRIGHT លោក CAYLEY និងលោក ROSANDHAUG ពិតជាទាក់ទិននឹងកិច្ចប្រជុំ និងថាតើ (ឬតាមមធ្យោបាយណា) កិច្ចប្រជុំទាំងនេះគួរត្រូវបន្តធ្វើនៅថ្ងៃមុខទៀត ឬយ៉ាងណា ដោយយោងតាមសាលដីកាលើបណ្តឹងសាទុក្ខនេះ។ ហេតុដូច្នេះ កិច្ចប្រជុំទាំងនេះ ពាក់ព័ន្ធជាមួយបញ្ហារដ្ឋបាល និងបញ្ហាគ្រប់គ្រងប៉ុណ្ណោះ ហើយពុំបានទាក់ទិនទៅនឹងខ្លឹមសារនៃសំណុំរឿង ០០២ ឬកិច្ចដំណើរការនីតិវិធីតាមផ្លូវការផ្សេងៗណាមួយឡើយ។ ដោយហេតុថា កិច្ចប្រជុំដែលពាក់ព័ន្ធនឹងបញ្ហារដ្ឋបាល និងបញ្ហាគ្រប់គ្រង និងបញ្ហាដែលមិនពាក់ព័ន្ធនឹងរឿងក្តីដូច្នេះនោះ វាពុំបានញ៉ាំងឱ្យមានមូលដ្ឋានណាមួយសម្រាប់ការដាក់ទណ្ឌកម្ម ឬបណ្តឹងជំទាស់ទេ ហើយការប្រាស្រ័យទាក់ទងការងារជាបន្តបន្ទាប់ក្រោយមកទៀត រវាងអ្នកចូលរួមទាំងប៉ុន្មាននៅក្នុងអង្គប្រជុំទាំងនេះ ក៏ពុំបង្កើតឱ្យមានមូលដ្ឋានសម្រាប់ការដាក់ទណ្ឌកម្ម ឬបណ្តឹងជំទាស់ដែរ។ បើទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សេចក្តីសម្រេចមួយត្រូវបានធ្វើដើម្បីបញ្ឈប់កិច្ចប្រជុំទាំងនោះ និងដើម្បីណែនាំដល់មេធាវីការពារជនជាប់ចោទ អៀង សារី និងភាគីផ្សេងៗថាបញ្ហារដ្ឋបាល និងបញ្ហាគ្រប់គ្រងដែលខ្លួនធ្លាប់បានព្យាយាមដោះស្រាយតាមរយៈអង្គប្រជុំទាំងនេះ ទៅថ្ងៃមុខគួរគប្បីត្រូវបានលើកដោយផ្ទាល់ទៅកាន់ផ្នែករដ្ឋបាលនៃ អ.វ.ត.ក[25]។

១៨. អង្គជំនុំជម្រះសាលាដំបូងបដិសេធនូវការចោទប្រកាន់របស់ជនជាប់ចោទ អៀង សារី ដែលថាសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី បានទទួលការយកចិត្តទុកដាក់ខុសគ្នាពីសំណាក់ចៅក្រម CARTWRIGHT[26]។ ក្រៅពីមធ្យោបាយធម្មតាសម្រាប់ការលើកបញ្ហាចំពោះអង្គជំនុំជម្រះ ឬការដាក់ឯកសារមកអង្គជំនុំជម្រះ គ្មានភាគីណាមួយនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ត្រូវបានអនុញ្ញាតឱ្យធ្វើការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយចៅក្រមអំពីបញ្ហានានាដែលទាក់ទិននឹងខ្លឹមសារនៃកិច្ចនីតិវិធីតាមផ្លូវតុលាការឡើយ។ ជនជាប់ចោទ អៀង សារី ពុំបានផ្តល់ភស្តុតាងណាមួយ ដើម្បីបង្ហាញថា ទម្លាប់អនុវត្តនេះត្រូវបានអនុវត្តដោយមិនត្រឹមត្រូវឡើយ។

---

[25] *សូមមើល ឧទាហរណ៍* ឧបសម្ព័ន្ធ៖ សារអេឡិចត្រូនិកពី Tanya Rene PETTAY ទៅ Susan LAMB, ឯកសារ E191/2.1 ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

[26] បណ្តឹង, កថាខណ្ឌ ៨, ១២-១៥។

១៩. យុត្តិសាស្ត្រអន្តរជាតិដែលជនជាប់ចោទ អៀង សារី បានលើកដើម្បីគាំទ្របណ្តឹងរបស់ខ្លួន បញ្ជាក់ថា បន្ទុកនៃការបង្ហាញភស្តុតាងចំពោះភាគីដែលស្នើសុំប្តឹងជំទាស់ទៅក្រម គឺជាបន្ទុកខ្ពស់[27]។ បន្ទុកនេះពុំទាន់ត្រូវបានបំពេញនៅឡើយទេ ក្នុងករណីបច្ចុប្បន្ននេះ។

២០. ទាក់ទិននឹងសំណើរបស់ជនជាប់ចោទ អៀង សារី ស្នើសុំដំណោះស្រាយជាជម្រើសផ្សេងមួយទៀត នៅក្នុងករណីដែលលក្ខខណ្ឌនៃភស្តុតាងសម្រាប់បណ្តឹងជំទាស់ ដោយអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុងពុំត្រូវបានបំពេញនោះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វិធាន ៣៤ ពុំបានចែងអំពីមូលដ្ឋានណាមួយ សម្រាប់ដំណោះស្រាយដែលជនជាប់ចោទបានស្នើសុំឡើយ។ មេធាវីការពារជនជាប់ចោទ អៀង សារី ពុំបានបញ្ជាក់អំពី មូលដ្ឋានគតិយុត្តណាមួយផ្សេងទៀត សម្រាប់ការផ្តល់ដំណោះស្រាយជាជម្រើសផ្សេងមួយទៀតនេះឡើយ[28]។ ថ្វីបើបណ្តឹងនេះយោងត្រួសៗទៅលើវិធាន៣៥ នៃវិធានផ្ទៃក្នុងក៏ដោយ ក៏ការប្រជុំជាមួយភាគីតែម្ខាង (តាមការសន្និដ្ឋាន និងការប្រាស្រ័យទាក់ទងការងារនានាពាក់ព័ន្ធនឹងកិច្ចប្រជុំទាំងនោះ) ដែលក្នុងនោះគ្មានបញ្ហាអ្វីពុំសមស្របដែលត្រូវបានចោទប្រកាន់ថាត្រូវបានពិភាក្សា ពុំញ៉ាំងឱ្យមានមូលហេតុដែលអាចឱ្យជឿបានថាមានការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ ដោយចេតនាពិតប្រាកដឡើយ[29]។ ហេតុដូច្នេះ អង្គជំនុំជម្រះពុំមានមូលដ្ឋានណាមួយដើម្បីចាត់វិធានការ ដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងឡើយ ហើយបដិសេធ សំណើសុំដំណោះស្រាយជាជម្រើសផ្សេងមួយទៀតនេះ[30]។

---

[27] បណ្តឹង,កថាខណ្ឌ ១១; សេចក្តីសម្រេចលើបណ្តឹងសាទុក្ខបន្ទាន់បង្ហំ *Karemera*, កថាខណ្ឌ ៦៧ (ដោយបានកត់សម្គាល់ថា ការរកឃើញនូវភាពលម្អៀងដោយប្រយោលនៅក្នុងសំណុំរឿងនោះគឺផ្អែកលើទំនាក់ទំនង និងការរួមរស់ជាប្តីប្រពន្ធរបស់ចៅក្រមមួយរូបជាមួយមន្ត្រីរដ្ឋអាជ្ញា; ការខកខានរបស់ចៅក្រមរូបនោះក្នុងការបញ្ចេញឱ្យដឹងអំពីបញ្ហានោះរហូតមកទល់នឹងពេលដែលមេធាវីការពារក្តីបានលើកបញ្ហានេះ; និងការស្ម័គ្រចិត្តរបស់ចៅក្រមរូបនោះក្នុងការដកខ្លួនចេញពីសំណុំរឿងនេះ)។

[28] បណ្តឹង, កថាខណ្ឌ១៧-១៩។

[29] បណ្តឹង, កថាខណ្ឌ ១៩ (ដោយបានស្នើសុំឱ្យការណែនាំ និងការបង្គាប់ដែលខ្លួនបានស្នើសុំ មាន "ការគំរាមអំពីទណ្ឌកម្មដោយអនុលោមតាមវិធាន ៣៥ នៅក្នុងពេលមានការរំលោភបំពាន")។

[30] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ, កថាខណ្ឌ ១៤,២៣; *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំឱ្យចាត់ការជាបន្ទាន់តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង, ឯកសារ E176/2, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២, កថាខណ្ឌ ២០ (ដែលបានកត់សម្គាល់ថា លក្ខខណ្ឌសម្រាប់ការចាត់វិធានការ ដោយអនុលោមតាមវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង គឺជំនឿដែលមានហេតុផលត្រឹមត្រូវថា បុគ្គលម្នាក់អាចបានជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលរបស់តុលាការ)។

២១. អង្គជំនុំជម្រះក៏បដិសេធសំណើរបស់ជនជាប់ចោទ អៀង សារី ដែលស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យចៅក្រម CARTWRIGHT និងលោក CAYLEY បញ្ចេញឱ្យដឹងនូវរាល់ការប្រាស្រ័យទាក់ទងការងារជាមួយ *ភាគីតែម្ខាង* រវាងពួកគាត់ចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។ តាមសំអាងហេតុដូចបញ្ជាក់ខាងលើ អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចណាមួយដើម្បីធ្វើការបង្គាប់ដូចខាងលើ ដោយអនុលោមតាមវិធាន ៣៤ ឬ វិធាន ៣៥ នៃវិធានផ្ទៃក្នុងឡើយ ហើយជនជាប់ចោទ អៀង សារី បានខកខានពុំបានបញ្ជាក់អំពីមូលដ្ឋានគតិយុត្តណាមួយផ្សេងនៃសំណើនេះ។ ជាងនេះទៅទៀត ពុំមានមូលដ្ឋានណាមួយដើម្បីឱ្យអង្គជំនុំជម្រះឯកភាពតាមសំណើនេះឡើយ ដោយហេតុថា ការប្រាស្រ័យទាក់ទងការងារនោះ ពុំមែនជាការពុំត្រឹមត្រូវឡើយ ហើយមេធាវីការពារជនជាប់ចោទ អៀង សារី ក៏ពុំមែនជាអ្នកចូលរួមនៅក្នុងកិច្ចពិភាក្សានានាពាក់ព័ន្ធនឹងកិច្ចការគ្រប់គ្រង និងកិច្ចការរដ្ឋបាលទូទៅនៃភាគីអន្តរជាតិនៃ អ.វ.ត.ក ដែរ។

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**បដិសេធ** បណ្តឹងរបស់ជនជាប់ចោទ អៀង សារី ប្តឹងជំទាស់ចិត្តចំពោះចៅក្រម CARTWRIGHT ។

**បដិសេធ** សំណើរបស់ជនជាប់ចោទ អៀង សារី ដែលស្នើសុំឱ្យអង្គជំនុំជម្រះណែនាំដល់ចៅក្រម CARTWRIGHT និងបង្គាប់ឱ្យលោក CAYLEY បញ្ឈប់ និងឈប់ការប្រាស្រ័យទាក់ទងការងារ និងការប្រជុំជាមួយ*ភាគីតែម្ខាង* និងចម្លងជូនអ្នកតំណាងនៃអង្គភាពគាំពារការការពារក្តី ឬក្រុមមេធាវីការពារក្តី នូវរាល់ព័ត៌មានស្តីពីការប្រាស្រ័យទាក់ទងការងារទាក់ទិននឹង អ.វ.ត.ក រវាងពួកគាត់។

**បដិសេធ** សំណើរបស់ជនជាប់ចោទ អៀង សារី ដែលស្នើសុំឱ្យអង្គជំនុំជម្រះណែនាំដល់ចៅក្រម CARTWRIGHT និងបង្គាប់ឱ្យលោក CAYLEY បញ្ចេញឱ្យដឹងអំពីការប្រាស្រ័យទាក់ទងការងារជាមួយ*ភាគីតែម្ខាង* រវាងពួកគាត់ចាប់តាំងពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

**ភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២**

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C.

និល ណុន